**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងរដ្ឋប្បវេណី ៣៣៣៧៣

លេខៈ ២៤៣

ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ **នាមនាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u> **តុលាការកំពូល**

លេខៈ ២៧១ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ដោយ

ចុះថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ២០០៣ មានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២-លោក ស៊ិន ឌឹម ជាចៅក្រម

៣-លោក ជីវ កេង ជាចៅក្រម

៤-លោក សោម សិរីវឌ្ឍ ជាចៅក្រមរបាយការណ៍

៥-លោក យូរ ឧត្តរា ជាចៅក្រម

ក្រឡាបញ្ជី

លោក **ស៊ិន នារៈ**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៣៦"ខ" ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ រវាង :

ដើមចោទឈ្មោះ **ខេង ខូច** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិទំនប់ ផ្លូវ១១២ ក្រុម៣ សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ប្រពន្ធឈ្មោះចុង រដ្ឋា ។

ផ្ទេរសិទ្ធិឱ្យឈ្មោះ ហេង កេសរោ ។

ចុងចម្លើយឈ្មោះ **សៀ គុយម៉ុង** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៨ឆ្នាំ មុខរបរ

ម៉ៅការសំណង់ ទីលំនៅភូមិស្វាយជ្រុំថ្មី ឃុំស្វាយជ្រុំ ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង ។

**កម្មវត្ថុបណ្តឹង** : ប្តឹងសុំមិនទូទាត់ថ្លៃសំណង់ ក្នុងដំណាក់កាលទី១ នៃកិច្ចសន្យា ។

បានឃើញបណ្តឹងសាទុក្ខលេខ ២០៨ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះចុង រដ្ឋា ជាប្រពន្ធរបស់ដើមចោទឈ្មោះ ខេង ទូច ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៣៦"ខ"ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៤៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី៣១-៥-១៩៩៩ របស់លោកខេង ទូច ប្តឹងសុំមិនទូទាត់ថ្លៃសំណង់ក្នុងដំណាក់កាលទី១នៃកិច្ចសន្យាពីលោកអៀ គុយម៉ុង ដោយអាងហេតុថា លោកអៀ គុយម៉ុង សាងសង់សំណង់មិនត្រឹមត្រូវ និងសុំមិនទូទាត់ថ្លៃសំណង់ដំណាក់កាលទី១ចំនួន១៥.០០០ដុល្លាអាមេរិក និងបញ្ឈប់ការសាងសង់ ។ សុំឱ្យប្រគល់ពាក្យស្នើសុំកាន់កាប់ដីធ្លីលេខ ២៨២ចុះថ្ងៃទី១២-៦-១៩៩៨ វិញ និងសុំទាមទារជំងឺចិត្តចំនួន ៣.០០០ដុល្លា ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៩៨"ក" ចុះថ្ងៃទី១០. ខែសីហា ឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ខេង ទូច ប្រពន្ធឈ្មោះចុង រដ្ឋា ចុះថ្ងៃទី៣១-៥-៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ រវាងអ្នកប្រគល់សិទ្ធិឈ្មោះខេង ទូច ប្រពន្ធឈ្មោះចុង រដ្ឋា និងអ្នកទទួលសិទ្ធិ មេធាវីឈ្មោះកែត ឃី ចុះថ្ងៃទី៣១-០៥-១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ និងគតិច្បាប់ ។

៣-ទទួលស្គាល់កិច្ចសន្យាប្រគល់ប្រាក់ចុះថ្ងៃទី១០-៤-១៩៩៩ រវាងឈ្មោះខេង ទូច-ចុង រដ្ឋា និងអ្នកទទួលឈ្មោះអៀ គុយម៉ុង និងលិខិតបញ្ចាំប្លង់ដី ចុះថ្ងៃទី០៤-៥-១៩៩៩ របស់ឈ្មោះអៀ គុយម៉ុង និងឈ្មោះខេង ទូច. ចុង រដ្ឋា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។ (តាមមាត្រា៥ ចំណុចទី៣ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា) ។

៤-ទទួលស្គាល់កិច្ចសន្យាសាងសង់កុដិចុះថ្ងៃទី២០-១២-៩៨ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ និងគតិច្បាប់ ។ (តាមមាត្រា ៣ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា) ។

៥-ដកសិទ្ធិភាគីឈ្មោះ អៀ គុយម៉ុង ភេទប្រុស អាយុ២៩ឆ្នាំ មានទំលំនៅភូមិស្វាយ

ជ្រុំថ្មី ឃុំស្វាយជ្រុំ ស្រុករលៀប្អៀរ ខេត្តកំពង់ឆ្នាំង ជាអ្នកទទួលម៉ៅការសំណង់កុដិនៅវត្តទួលកែវ តាមកិច្ចសន្យាខាងលើលែងឱ្យអនុវត្តកិច្ចសន្យានេះ ក្នុងដំណាក់កាលទី២ ,ទី៣, ទី៤, ទី៥,ទី៦, តទៅទៀត (តាមមាត្រា២៩ នៃក្រិត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា ) ។

៦-សំណង់ក្នុងដំណាក់កាលទី១ ដែលបានសាងសង់ហើយតំលៃ ១៥.០០០$ ឈ្មោះ អៀគុយម៉ុង ទទួលសងខ្លួនឯង ដោយមិនត្រូវទាមទារពីឈ្មោះខេង ទូច,ចុង រដ្ឋា ឡើយ ហើយឈ្មោះ អៀ គុយម៉ុង ត្រូវវាយកំទេចចោលដោយខ្លួនឯង រួចរើសយកសំភារៈដែលអាចយកទៅប្រើបាន ទៅប្រើប្រាស់ដោយខ្លួនឯង ។ លើសពីនេះទៀត ឈ្មោះអៀ គុយម៉ុង ត្រូវសងថ្លៃអាងទឹកដែលខូចខាតជាប្រាក់ចំនួន២.០០០$(ពីរពាន់ដុល្លាអាមេរិក) ការយឺតយ៉ាវក្នុងការសាងសង់ និងជម្ងឺចិត្តចំនួន ១០.០០០.០០០៛ (ដប់លានរៀលគត់) ព្រមទាំងប្រគល់ពាក្យសុំកាន់កាប់ដីឈ្មោះខេង ទូច ប្រពន្ធឈ្មោះចុង រដ្ឋា ចុះថ្ងៃទី ១២-៦-១៩៩៩ ឱ្យទៅដើមចោទវិញ ការទាមទារលើសពីនេះរបស់ដើមចោទលើកចោល ( តាមមាត្រា ២២ នៃក្រិត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា) ។

៧-នៅពេលសាលក្រមនេះចូលស្ថាពរ ,បើឈ្មោះអៀ គុយម៉ុង មិនបានអនុវត្តតាមខ្លឹមសារចំនុចទី៦ ខាងលើនេះទេ ដើមចោទឈ្មោះខេង ទូច ប្រពន្ធឈ្មោះ ចុង រដ្ឋា មានសិទ្ធិវាយកំទេចសំណង់ជំហានទី១នេះ ដោយមិនទទួលខុសត្រូវលើដែកដែលមានស្រាប់ ហើយឱ្យឈ្មោះអៀ គុយម៉ុង ចេញសោហ៊ុយរុះរើនោះជាប្រាក់ចំនួន៥០០$ (ប្រាំរយដុល្លាអាមេរិក) បន្ថែមទៀត ។ ចំពោះប្រាក់ចំនួន ២.០០០$ (ពីរពាន់ដុល្លាអាមេរិក) ជម្ងឺចិត្ត១០.០០០.០០០៛(ដប់លានរៀលគត់)និងសោហ៊ុយរុះរើ៥០០$ (ប្រាំរយដុល្លាអាមេរិក) បើឈ្មោះអៀ គុយម៉ុង មិនព្រមអនុវត្តទេ តុលាការនឹងរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុ របស់ឈ្មោះអៀ គុយម៉ុង លក់ឡាយឡុងដើម្បីសងប្រាក់ទៅដើមចោទ ។ ករណីរឹងរូស ឬមានឧបាយកលទុច្ចរិត តុលាការនឹងចាប់បង្ខំរូបកាយឈ្មោះអៀ គុយម៉ុង ដាក់ពន្ធនាគារចំនួន ៨ខែ (តាមមាត្រា២២,២៤ នៃក្រិត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងមាត្រា១៣៣ នៃច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ) ។

៨-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛ ពីដើមចោទ ដែលប្រាក់នេះ ដើមចោទបានបង់រួចហើយ ពេលសាលក្រមចូលស្ថាពរ បង្គាប់ឱ្យចុងចំលើយបង់សងវិញ និង ឱ្យបង់ពន្ធសមាមាត្រ១% បន្ថែមទៀតស្មើ $\frac{1\,(15.000\ +2.000+500+10.000.000)}{100}$ =១៧៥ និង ១០០.០០០៛ ។ ប្រាក់នេះដាក់ចូលថវិការដ្ឋ ៨០% និងបានរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។ ប្រាក់នេះតំរូវឱ្យដើមចោទបង់ទុកជាមុនសិន ទើបបង្គាប់ឱ្យចុងចម្លើយបង់សងវិញជាក្រោយ ។

៤-សាលក្រមនេះ ប្រកាសជាសាធារណៈនៅចំពោះមុខដើមចោទទទួលសិទ្ធិ គឺមេធាវីឈ្មោះ កែត ឃី កំបាំងមុខចុងចម្លើយ ដោយទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

បានឃើញបណ្តឹងទាស់លេខ ៦១ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩ របស់ឈ្មោះអៀ គុយម៉ុង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៩៨"ក" ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ចាម ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៣២"ក" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ដើមចោទ និង សាលក្រមកំបាំងមុខរបស់ចុងចម្លើយឈ្មោះ អៀ គុយម៉ុង ចុះថ្ងៃទី២០-៨-៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមកំបាំងមុខលេខ ៩៨"ក" ចុះថ្ងៃទី១០-៨-៩៩ របស់តុលាការខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល ដោយគ្រាន់តែប្តូរឈ្មោះដើមចោទពីឈ្មោះចុង រដ្ឋា មកឈ្មោះ ហេង កេសរោ ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខរបរក្រឡាបញ្ជីសាលាឧទ្ធរណ៍ ទីលំនៅសព្វថ្ងៃផ្ទះលេខ សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ វិញ តាមការព្រមព្រៀងរបស់ឈ្មោះចុងរដ្ឋា និងឈ្មោះហេង កេសរោ តែប៉ុណ្ណោះ ។

៣-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខមេធាវីជាតំណាងដើមចោទ និងចុងចម្លើយដោយទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៧៧ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៩ របស់ឈ្មោះអៀគុយម៉ុង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៣២"ក" ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ចាម ត្រង់ចំណុចសាលក្រមទាំងមូល ដោយហេតុថា តុលាការខេត្តកំពង់ចាមជំនុំជំរះរឿងក្តីរបស់ខ្លួនគ្មានភាពយុត្តិធម៌ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៦"ខ" ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៦-១០-១៩៩៩ របស់ឈ្មោះ អៀ គុយម៉ុង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីកំបាំងមុខលេខ ៩៨"ក" ចុះថ្ងៃទី១០-៨-៩៩ និង

សាលក្រមរដ្ឋប្បវេណីលេខ១៣២"ក"ចុះថ្ងៃទី០៦-១០-៩៩ របស់តុលាការខេត្តកំពង់ចាមចោលជាអសារបង់ ។

៣-ក/ទទួលស្គាល់កិច្ចសន្យាប្រគល់ប្រាក់ចុះថ្ងៃទី១០-៤-៩៩ របស់ឈ្មោះ ខេង ទូច និងនាង ចុង រដ្ឋា និងលិខិតបញ្ចាំប្លង់ដីរបស់ឈ្មោះ ខេង ទូច និងនាង ចុង រដ្ឋា ទុកជាត្រឹមត្រូវតាមច្បាប់ ។

ខ/ទទួលស្គាល់កិច្ចសន្យាសាងសង់ចុះថ្ងៃទី២០-១២-៩៨ រវាងឈ្មោះខេង ទូច និង ចុង រដ្ឋា និងឈ្មោះអៀ គុយម៉ុង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-បង្គាប់អោយឈ្មោះអៀ គុយម៉ុង អនុវត្តតាមរបាយការណ៍ត្រួតពិនិត្យការសាងសង់សំណង់ចុះថ្ងៃទី១៥-៩-៩៩ របស់ក្រុមវិស្វករសំណង់ដែលបានចុះត្រួតពិនិត្យកាលពីថ្ងៃទី១០-៦-៩៩ ឱ្យបានចប់តាមកាលកំណត់ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៥-កាលបើឈ្មោះអៀ គុយម៉ុង អនុវត្តតាមចំណុចទី៤ ខាងលើនេះចង់សព្វគ្រប់ហើយ បង្គាប់ឱ្យឈ្មោះខេង ទូច និងនាងចុង រដ្ឋា ប្រគល់ប្រាក់ថ្លៃសាងសង់សំណង់នៅដំណាក់កាលទី១ ចំនួន ១៥.០០០ដុល្លាអាមេរិក ឱ្យទៅឈ្មោះអៀ គុយម៉ុង គ្រប់ចំនួន រួចហើយបង្គាប់ឱ្យឈ្មោះ អៀ គុយម៉ុង ប្រគល់ប្លង់ដីដែលដាក់បញ្ចាំទៅឱ្យឈ្មោះខេង ទូច និងនាង ចុង រដ្ឋា វិញ ។

៦-ក្រោយពីបានទទួលប្រាក់គ្រប់ចំនួនក្នុងចំណុចទី៥ ខាងលើនេះហើយ ត្រូវបញ្ឈប់ឈ្មោះអៀ គុយម៉ុង មិនឱ្យសាងសង់សំណង់ក្នុងដំណាក់កាលទី២,៣,៤ តទៅទៀតទេ ។

៧-បង្គាប់ឱ្យឈ្មោះអៀ គុយម៉ុង ជួសជុលអាងទឹកដែលប្រើការមិនបានល្អឱ្យមានភាពរឹងមាំនិងប្រើការបានល្អ ត្រឹមត្រូវឡើងវិញ ។

៨-កាត់យកប្រាក់ប្រដាប់ក្ដីចំនួន ១៣.០០០រៀល ដែលឈ្មោះអៀ គុយម៉ុង បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វឹង២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល និងអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ។

នៅពេលសាលដីកានេះចូលជាស្ថាពរ បង្គាប់ឱ្យឈ្មោះខេង ទូច និងនាង ចុង រដ្ឋា សងប្រាក់ប្រដាប់ក្ដីចំនួន ១៣.០០០រៀលឱ្យទៅឈ្មោះអៀ គុយម៉ុង វិញ និងបង់ពន្ធសមាមាត្រចំនួន ១ភាគរយលើទឹកប្រាក់ចំនួន ១៥.០០០ដុល្លាអាមេរិក ហើយប្រាក់នេះបានជាប្រយោជន៍ដល់ថវិការដ្ឋ៨០ភាគរយនិងបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

សាលដីកានេះ ជំនុំជំរះ នៅថ្ងៃទី១៣-៣-២០០០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២០-៣-២០០០ ចំពោះមុខដើមបណ្តឹងឧទ្ធរណ៍កំបាំងមុខចុងបណ្តឹងឧទ្ធរណ៍សំរេចបើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ ៦ ខែ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២០៨ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះចុង រដ្ឋា ជាប្រពន្ធរបស់ដើមចោទឈ្មោះ ខេង ទូច ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៣៦"ខ"ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះហេង គេសរោ ជាតំណាងឱ្យដើមចោទ ។

បានឃើញសារណាតបចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះអៀ គុយម៉ុង ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :សាលដីការដ្ឋប្បវេណីលេខ ៣៦"ខ" ចុះថ្ងៃទី២០-៣-២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ និងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសំរេច ។

បានស្តាប់ចំលើយរបស់ឈ្មោះចុង រដ្ឋា តំណាងឱ្យដើមចោទ(ជាម្ចាស់បណ្តឹងសាទុក្ខ) នាពេលជំនុំជំរះថា : ខ្លួនមិនសុខចិត្តនិងការសំរេចរបស់សាលាឧទ្ធរណ៍ដែលបានឱ្យខ្លួនជួសជុលសំណង់ឡើងវិញ ហើយបានឱ្យខ្លួនចេញលុយទៅឱ្យអៀ គុយម៉ុង ខ្លួនមិនព្រមទេ ។ ក្រោយពេលដែលខ្លួនចុះទៅពិនិត្យឃើញថា ការសាងសង់អាងទឹក និងការសាងសង់ជំណាក់កាលទី១ មិនត្រឹមត្រូវតាមបច្ចេកទេស និងប្លង់ទេ ដោយហេតុថា : ក្នុងប្លង់បានកំណត់បាតជើងគ្រឹះត្រូវបង្ហាប់ថ្ម ៤ x ៦ លាយជាមួយបាយអរកំរាស់ ១៥សង់ទីម៉ែត្រ តែភាគីលោកអៀ គុយម៉ុង មិនអនុវត្តតាមបែរជាដាក់ខ្សាច់ជំនួសទៅវិញ ។

- ជើងសរសរតឿតាមប្លង់ត្រូវកាច់ជាជើងក្រុឌ តែភាគីលោកអៀគុយម៉ុង បែរជាកាច់ជាជើងមាន់ទៅវិញ ។

- កញ្ច្រែងបាតគ្រឹះ ត្រូវដាក់ដែកចំនួន៦ដើម ទំហំ ១០លី និងដែកចំនួន៥ដើម ទំហំ១២លី តែភាគីលោកអៀ គុយម៉ុងបែរជាដាក់ដែកចំនួន ៥ដើម ទំហំ ១០លីទៅវិញ ។ ចំណែកធ្នឹមក្រោមតាមប្លង់ត្រូវដាក់ដែកចំនួន៦លី ទំហំ ១៦លី និងក្រាលថ្មទំហំ៤ x ៦ដោយលាយជាមួយបាយអរ កំរាស់១២សង់ទីម៉ែត្រពីក្រោមដើម្បីធ្វើជាគ្រឹះធ្នឹមសំរាប់ទ្រធ្នឹម តែភាគីលោក អៀ គុយម៉ុង បែរជាដាក់ដែកចំនួន

៤ដើម ទំហំ ១៦លី និងដាក់ដែកចំនួនពីរដើម ទំហំ ១៤លី និងមិនបានដាក់ថ្ម លាយជាមួយបាយអរពីក្រោមធ្នឹមទេ ។ ខ្លួនសុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានស្ដាប់ចំលើយរបស់ឈ្មោះ ហេង កេសរោ តំណាងឱ្យដើមចោទ(ជាម្ចាស់បណ្ដឹងសាទុក្ខ)នាពេលជំនុំជំរះថា : ខ្លួនបានប្រគល់សិទ្ធិឱ្យដើមចោទ គឺអ្នកស្រីចុង រដ្ឋា វិញហើយ សូមក្រុមប្រឹក្សាជំរះសំរេចតាមច្បាប់ចុះ ។

បានស្ដាប់ចំលើយរបស់ឈ្មោះអៀ គុយម៉ុង (ជាចុងបណ្ដឹងសាទុក្ខ) នាពេលសវនាការថា : នៅក្នុងដំណាក់កាលទី១ គឺបញ្ហាបុកគ្រឹះចាក់ធ្នឹមក្រោមរួចភាគីខាង ខេង ទូច និងប្រពន្ធឈ្មោះចុង រដ្ឋា ត្រូវប្រគល់ប្រាក់មកឱ្យភាគីខ្លួនចំនួន ១៥.០០០ដុល្លាអាមេរិក ។ ដូច្នេះខ្លួនសុំឱ្យភាគីអ្នកស្រី ចុង រដ្ឋា សងប្រាក់ឱ្យខ្លួន១៥.០០០ដុល្លាអាមេរិក ។ ការសាងសង់មានប្លង់ មានមេភូមិ មានអាចារ្យវត្ត មានប្រជាជននៅទីនោះដែរ ។ ដូចមានរបាយការណ៍ចុះថ្ងៃទី០២-០៤-១៩៩៩ របស់គណៈកម្មការអាចារ្យវត្តទួលកែវ ដែលបានចុះពិនិត្យសាងសង់នោះបញ្ជាក់ថា អ្នកម៉ៅការសាងសង់បានសាងសង់ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសនិងតាមប្លង់ហើយ ។ក្នុងការសាងសង់នោះ ខ្លួនបានជួបឧបសគ្គខ្លះក៏ដោយ ដូចមានលក្ខណៈភូមិសាស្ត្រមិនអំណោយផល ដីខ្លះខ្ពស់ ដីខ្លះទាប បូកបញ្ចូលយកពាក់កណ្ដាល ខ្លួនបានខិតខំធ្វើយ៉ាងយកចិត្តទុកដាក់បំផុត ទៅតាមគំនូរប្លង់រហូតសំរេចលទ្ធផល ១០០% ។ ព្រោះនៅពេលសាងសង់នោះមានគណៈកម្មការធ្វើការនៅទីនោះរហូតពេលដែលខ្លួនធ្វើខុសគេផ្អាក ហើយមិនឱ្យសង់បន្តទៀតទេ ។ ខ្លួនសំណូមពរតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោកសែម ចិន្ដា មេធាវីដើមចោទបានលើកឡើងថា : ខ្លួនជាមេធាវីការពារឱ្យអ្នកស្រីចុង រដ្ឋា ដែលទាក់ទង នឹងបណ្ដឹងសាទុក្ខពីសាលដីកាសាលាឧទ្ធរណ៍ ខ្លួនយល់ឃើញថា :

-អំពីភស្ដុតាងកិច្ចសន្យាសាងសង់អំពីគ្រឹះនៃវិហារទួលកែវ មានចុះកិច្ចសន្យា៤ប្រការ :

+ ក្នុងប្លង់បានកំណត់បាតជើងគ្រឹះ ត្រូវបង្ហាប់ថ្ម ៤ x ៦ លាយជាមួយបាយអរ តែភាគីលោកអៀ គុយម៉ុង បែរជាដាក់ខ្សាច់ទៅវិញ ។

+ ជើងសរសរតាមប្លង់ត្រូវកាច់ជាជើងគ្រុឌ តែភាគីលោកអៀគុយម៉ុង បែរជាកាច់ជាជើងមាន់ទៅវិញ ។

+ បាតកញ្ច្រែងពីខាងក្រោមតំរូវឱ្យដាក់ថ្ម លាយជាមួយបាយអរជាក់ស្ដែងអត់មាននៅបាតកញ្ច្រែងមានខ្សាច់ទៅវិញ ។

+បើពិនិត្យទៅលើផ្ទឹមចាក់ភ្ជាប់ពីសរសរមួយទៅសរសរមួយនៅក្រោមផ្ទឹមលាយថ្ម៤x៦ ជាក់ស្តែងអត់មាន ។

+ការសាងសង់ខុសមិនប្រក្រតីមានការបញ្ជាក់ចុះថ្ងៃទី១០-១០-១៩៩៦ ក៏នៅតែទទួលស្គាល់ការសាងសង់ខុសបច្ចេកទេស ។

ខ្លួនសុំតម្កល់របាយការណ៍លេខ ១០-១០-១៩៩៦ និងសុំតម្កល់សាលក្រមរបស់តុលាការខេត្តកំពង់ចាម ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវ តាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២០៨ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០០ របស់អ្នកស្រី ចុងរដ្ឋាធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៨នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា សាលាឧទ្ធរណ៍សំរេចទទួលស្គាល់កិច្ចសន្យាសាងសង់ចុះថ្ងៃទី២០-១២-១៩៩៨ របស់គូភាគីហើយ ប៉ុន្តែសាលាឧទ្ធរណ៍បែរជាសំរេចឱ្យឈ្មោះអៀ គុយម៉ុង អនុវត្តតាមរបាយការណ៍ត្រួតពិនិត្យចុះថ្ងៃទី១៥-៩-១៩៩៩ របស់ក្រុមវិស្វករសំណង់ទៅវិញនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះរបាយការណ៍ត្រួតពិនិត្យនេះ ពុំមែនជាច្បាប់របស់គូភាគីដូចមានចែងក្នុងមាត្រា២២ នៃក្រឹត្យច្បាប់លេខ៣៨ក្រច ចុះថ្ងៃទី២៨-១០-១៩៨៨ ទេ ។ ដូច្នេះ តុលាការគប្បីសំរេចឱ្យគូភាគីអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃកិច្ចសន្យាចុះថ្ងៃទី២០-១២-១៩៩៨ របស់គូភាគី ។

- យល់ឃើញថា សាលដីកាវដ្តប្បវេណីលេខ៣៦"ខ" ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ២០៨ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៣ របស់អ្នកស្រីចុង រដ្ឋា ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៣៦"ខ" ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៣ របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៤៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ របស់តុលាការ កំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលលោកអៀ គុយម៉ុង បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី នឹង ពន្ធហ្វឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ។

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ ។